

# វិធីបណ្ដុះកូនល្ហុង

## ១-ការជ្រើសរើសពូជ:

- ❋ យើងត្រូវជ្រើសរើសដើមល្ហុងធំល្អ ស្លឹកខៀវចាស់ មិនមានរោគហើយយកផ្លែដែលធំវែង មានសំបុរ ពណ៌លឿង មួយឆ្នូត។
- ❋ ពុះផ្លែល្ហុងជាបណ្ដោយចំពាក់កណ្ដាលហើយឆ្កឹះយកគ្រាប់ល្ហុងចេញអោយអស់។
- ❋ រើសយកតែគ្រាប់ណាធំៗ ល្អមានពណ៌ ខ្មៅ ឬ ប្រផេះ បន្ទាប់មកច្របាច់ស្រទាប់គ្រាប់ចេញ ហើយលាងទឹកអោយស្អាត។
- ❋ យកគ្រាប់ទៅប្រឡាក់ ជាមួយផេះចង្រ្កាន (គឺយកផេះចាស់៧-១០ថ្ងៃ) អោយសព្វគ្រាប់ល្ហុងរួចយកមកពង្រាយ លើក្រដាស់កាសែតស្តើងៗដើម្បីអោយគ្រាប់រហ័យ ស្ងួត។





- ❋ សំដិលក្នុងម្លប់ មិនអោយត្រូវពន្លឺថ្ងៃ និងឧស្សាហ៍ជ្រោយត្រឡប់វា២ ទៅ ៣ដង ក្នុង១ថ្ងៃដើម្បីកុំអោយគ្រាប់ដុះផ្សិត។
- ❋ ទុកពី៧ ទៅ១០ថ្ងៃ យើងអាចយកគ្រាប់មកបណ្ដុះបានហើយ បើយើងទុកគ្រាប់យូរពេក វាមិនអាចដុះបានល្អទេ។

## ២- ការបណ្ដុះគ្រាប់:

យើងយកគ្រាប់ដែលហាលស្ងួតមកត្រាំ ទឹកចំនួន២ យប់បន្ទាប់មកស្រង់គ្រាប់ចេញយកជី រ៉េត ចំនួន ១០០cc លាយទឹក ២០L មកត្រាំគ្រាប់ ល្ហុងរយៈ ពេល ២ម៉ោងទៀត ទើបយើងស្រង់វា ចេញយកមកបណ្ដុះក្នុងកន្ទោង ឬថង់តែម្ដង។ ការត្រាំគ្រាប់ជាមួយ ជីរ៉េត ធ្វើឲ្យគ្រាប់ដុះបានល្អហើយជួយការពារ ជំងឺរោគល្ហុងបានផង។



## ៣- ការរៀបចំដីដាក់ក្នុងកន្ទោងបណ្ដុះ ៖

- ❋ យើងត្រូវយកដីផុសល្អចំនួន ៤ធុងស្ដិចត្រូលាយ ជាមួយអាចម៍គោស្ងួតផុសចំនួន ១ធុងស្ដិចត្រូ និងលាយជាមួយផេះអង្កាម( យកផេះចាស់១ឆ្នាំ ) ចំនួន១ធុងស្ដិចត្រូដែរ រួចយកមកលាយច្របល់ចូលគ្នាអោយសព្វល្អ។




- ❋ យកថង់ទំហំ ៤ x ៧cm មកកាត់គែមគូថទាំងសងខាងចេញហើយយកដីដែលលាយរួចមកច្រកចូល ក្នុងកន្ទោងថង់ជិតពេញ រួចដាក់គ្រាប់ពូជចំនួន ២គ្រាប់ចំកណ្ដាលទន្ទឹមគ្នាហើយយក

ដី មករោយពីលើគ្រាប់ជាការស្រេច។

- ត្រូវធ្វើរងទទឹង ១ម៉ែត្រ និងបណ្តោយទៅតាមការពេញចិត្តរបស់យើង។
- តម្រៀបកន្ទោងថង់ជាជួរអោយពេញរង។ត្រូវយក ស្បៃពណ៌បៃតង ៦០% មកប្រក់ពីលើរង។
- ត្រូវស្រោចទឹកជារៀងថ្ងៃនៅពេលល្ងាចអោយជោគល្មមរហូតដល់គ្រាប់ដុះចេញពន្លក។
- កូនល្ហុងអាចដុះក្នុងរយៈពេលពី ១០-១៥ថ្ងៃ។

## ៤- ការថែទាំកូនល្ហុងក្នុងកន្ទោងៈ

- ពេលកូនល្ហុងដុះមានសន្លឹក ២-៣ សន្លឹកយើងត្រូវបាញ់ថ្នាំការពារសត្វល្អិត ណ៉ាតូ៊ ក្នុងកំរិតប្រើ ៣០cc លាយជាមួយទឹក ១៦L បាញ់ទៅលើកូនល្ហុងអោយសើមល្មម។
- ត្រូវស្រោចទឹករហូតដល់ពេលដែលត្រូវយកកូនល្ហុងទៅដាំ បើមានភ្លៀងធ្លាក់យើងត្រូវយកទឹក ធម្មតាមកស្រោចលាងស្លឹក និងដើមល្ហុងចេញ បើយើងមិនលាងចេញទេវាបណ្តាលអោយកូនល្ហុង រលួយ។



- បើមានស្មៅដុះក្នុងកន្ទោងតាមគែមរងយើងត្រូវដកវាចេញអោយអស់ដើម្បីអោយស្រឡះទើបកូនល្ហុងរីកធំធាត់លឿន។
- ត្រូវបាញ់ថ្នាំ ការពារសត្វល្អិតរៀងរាល់ ៥-៧ ថ្ងៃ ម្តងរហូតដល់កូនល្ហុងធំអាចយកដាំបាន។
- ពេលកូនល្ហុងដុះបាន ៤-៦សន្លឹក យកជីទឹក (វ៉េគ)ចំនួន ១០០cc លាយទឹក ២០Lបាញ់ពីលើកូនល្ហុងដើម្បីជួយអោយដើមរឹងមាំ និងមានសុខភាពល្អ។ មុនពេលបាញ់ជីត្រូវស្រោចទឹកកូនល្ហុង ឲ្យជោគសិនទើបយើងបាញ់ជី។

បញ្ជាក់: យើងបាញ់ ជីនេះតែម្តង គត់។

## ឯកសារពិគ្រោះ៖


- Traing module on fruit tree production, 2013 (គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ នៅខេត្តតំបន់ពាយព្យ)
- បទពិសោធន៍ ជួប វិចិត្រ កសិករដាំល្ហុង, 2012 (ឃុំតាគ្រែ ស្រុកកំរៀង ខេត្តបាត់ដំបង)



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោមៈ
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧




ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# បទពិសោធន៍ជោគជ័យ ក្នុងការបណ្តុះកូនល្ហុងរបស់កសិករគំរូ




សហការផលិតដោយ៖
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប
ឆ្នាំ២០១៣